អគ្គិសនីកម្ពុជា

លេខ : ៩៧៥/ណាន.អកក.អច

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

# សេចក្តីណែនាំ

**យោង:** - គោលការណ៍លេខ៩៩៥១ អក.អច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការយកកម្រៃសេវា ផ្តាច់-ភ្ជាប់ ការផ្គត់ផ្គង់អគ្គិសនីជូនអតិថិជនប្រើប្រាស់អគ្គិសនីពីអគ្គិសនីកម្ពុជា នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ភ្នំពេញ និងនៅតាមបណ្តាអង្គភាពអគ្គិសនីខេត្ត ចំណុះអគ្គិសនីកម្ពុជា។

- តារាងថ្លៃបន្តចរន្ត និងប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ(១)។

**អគ្គិសនីកម្ពុជា**សូមជម្រាប លោកនាយកអាជីវកម្មចែកចាយ ប្រធានសាខាអគ្គិសនីនៅភ្នំពេញ ប្រធានមជ្ឈមណ្ឌលបញ្ជា ប្រធានការិយាល័យម៉ាយែតទីង និងប្រធានអង្គភាពអគ្គិសនីខេត្ត ចំណុះអគ្គិសនីកម្ពុជា ឲ្យអនុវត្តតាមការណែនាំមានដូចខាងក្រោម:

**ក.អនុវត្តតាមគោលការណ៍ថ្មី:**

- គោលការណ៍លេខ៩៩៥១ អក.អច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការយកកម្រៃសេវា ផ្តាច់-ភ្ជាប់ ការផ្គត់ផ្គង់អគ្គិសនីជូនអតិថិជនប្រើប្រាស់អគ្គិសនី ពីអគ្គិសនីកម្ពុជា នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ភ្នំពេញ និងនៅតាមបណ្តាអង្គភាពអគ្គិសនីខេត្ត ចំណុះអគ្គិសនីកម្ពុជា។
- តារាងថ្លៃបន្តចរន្ត និងប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ(១)។

**ខ.និរាករណ៍គោលការណ៍ចាស់ និងសេចក្តីសម្រេច:**

- សេចក្តីសម្រេចលេខ១៤៧៤ សសរ.អក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការកំណត់ តម្លៃសេវាផ្សេងៗ ជូនអតិថិជន នៅអគ្គិសនីភ្នំពេញ និងតាមបណ្តាញអគ្គិសនីខេត្ត នៃអគ្គិសនីកម្ពុជា។
- គោលការណ៍លេខ៧៤៨៧ គក.អក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការយកកម្រៃសេវា ផ្តាច់-ភ្ជាប់ អគ្គិសនី ពីអគ្គិសនីកម្ពុជានៅក្នុងប្រព័ន្ធផ្គត់ផ្គង់ភ្នំពេញ និងនៅតាមបណ្តាអង្គភាពអគ្គិសនីខេត្ត ចំណុះអគ្គិសនីកម្ពុជា។
- តារាងថ្លៃបន្តចរន្ត និងប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ(១)។

សេចក្តីណែនាំនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ តទៅ។ អាស្រ័យហេតុនេះ សូមលោកនាយកអាជីវកម្មចែកចាយ ប្រធានសាខាអគ្គិសនីនៅភ្នំពេញ ប្រធានមជ្ឈមណ្ឌលបញ្ជា ប្រធានការិយាល័យម៉ាយែតទីង និងប្រធានអង្គភាពអគ្គិសនីខេត្ត ចំណុះអគ្គិសនីកម្ពុជា ចាប់អនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ តាមការណែនាំនេះ ដោយឈរលើស្មារតីទទួលខុសត្រូវ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ_រតនៈ**

**ចម្លងជូន**

-អគ្គនាយករងអគ្គិសនីកម្ពុជា

-គ្រប់នាយដ្ឋាន នៃអគ្គិសនីកម្ពុជា

-ការិយាល័យ-អង្គភាព-អគ្គិសនីខេត្ត នៃអគ្គិសនីកម្ពុជា

"ដើម្បីជ្រាបជាពត៌មាន"

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៩៩៥១ អក.៥២

# គោលការណ៍

## ស្តីពីការយកកម្រៃ សេវា ផ្តាច់-ភ្ជាប់ ការផ្គត់ផ្គង់អគ្គិសនីជូនអតិថិជន ប្រើប្រាស់អគ្គិសនី ពីអគ្គិសនីកម្ពុជា នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ភ្នំពេញ និងនៅតាមបណ្តាអង្គភាពអគ្គិសនីខេត្ត ចំណុះឲ្យអគ្គិសនីកម្ពុជា

- បានឃើញ ព្រះរាជក្រិត្យ ជស/រកត/០៣៩៦/១០របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ចុះ ថ្ងៃទី ០៩/០៣/១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវ មានកំណត់មួយរបស់រដ្ឋ ។

- បានឃើញ ព្រះរាជក្រិត្យ នស/រកត/០៨០៨/៩៨៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហមុនី ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ។

- បានឃើញ សេចក្តីសម្រេចលេខ ៤៦១ សរ.១៥ អអក របស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញ ភាពចាំបាច់ ដើម្បីធានានូវប្រសិទ្ធិភាព នៃការធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីជូនអតិថិជន

**ប្រការ ១** កំណត់យកថ្លៃសេវាផ្តាច់-ភ្ជាប់ការផ្គត់ផ្គង់ចរន្តអគ្គិសនី លើទីតាំងប្រើប្រាស់អគ្គិសនីដែលជាប់ជំពាក់ថ្លៃប្រើប្រាស់អតិថិជនហួសកាលកំណត់ នៅក្នុងវិក្កយបត្រប្រើប្រាស់ប្រចាំខែ:

- **អតិថិជនតង់ស្យុងទាប** ១០,០០០ រៀល ក្នុង ១ដង
- **អតិថិជនតង់ស្យុងមធ្យម** ២០,០០០ រៀល ក្នុង ១ដង

**ប្រការ ២** កំណត់យកថ្លៃសេវាសុំផ្អាកការប្រើប្រាស់អគ្គិសនីបណ្តោះអាសន្ន

- **គ្រប់ទំហំអំពែរ និងគ្រប់ប្រភេទអតិថិជន** ៤០,០០០ រៀល ក្នុង ១ដង

**ប្រការ៣** កំណត់យកថ្លៃសេវាពិនិត្យផ្ទៀងផ្ទាត់លេខអំណាននាឡិកាស្ទង់( ករណីពិនិត្យឃើញថាស្រង់លេខអំណាននាឡិកាស្ទង់ត្រឹមត្រូវ អ្នកប្រើប្រាស់ត្រូវបង់ថ្លៃសេវាផ្ទៀងផ្ទាត់។ករណីពិនិត្យឃើញថាស្រង់លេខអំណាននាឡិកា ស្ទង់ខុស អ្នកប្រើប្រាស់ ពុំតម្រូវឲ្យបង់ថ្លៃសេវាទេ ។

- ប្រភេទលំនៅដ្ឋានធម្មតា ៥,០០០ រៀល ក្នុង ១ដង
- ប្រភេទក្រៅលំនៅដ្ឋានធម្មតា ១០,០០០ រៀល ក្នុង ១ដង

**ប្រការ ៤** ចំណូលនៃសេវានេះ ត្រូវបង់ចូលបេឡានៃអង្គភាពនីមួយៗទាំងស្រុង ។

**ប្រការ ៥** អង្គភាពនីមួយៗ ត្រូវរៀបចំបែបបទតាមគោលការណ៍ គណនេយ្យ-ហិរញ្ញកិច្ច ដកចំណូលសេវាខាងលើសំរាប់ឧបត្ថមដល់ការបំពេញភារកិច្ច របស់អង្គភាពផ្ទាល់ ចំនួន ៦០% នៃចំណូលសេវាប្រចាំខែ ។

**ប្រការ ៦** សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ហេតុដល់មានការសម្រេចជាថ្មី និងនិរាករណ៍ នូវសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ [illegible] ឆ្នាំ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

# តារាងថ្លៃបន្តចរន្ត និងប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ (១)

| អាំងតង់ស៊ីតេស្នើសុំប្រើប្រាស់ ph x A | ប្រភេទអតិថិជន "លំនៅដ្ឋាន-អគាររដ្ឋបាល" | | | ប្រភេទអតិថិជន "អាជីវកម្ម-សិប្បកម្ម" | | | ប្រភេទអតិថិជន "ផ្ទះថ្វាយបរទេស-ស្ថានទូត-សណ្ឋាគារ" | | | រយៈពេលផ្តល់សេវា (២) |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្លៃបន្តចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | ថ្លៃបន្តចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | ថ្លៃបន្តចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | |
| **1 x 5** | 31,000 | 31,000 | **62,000** | 31,000 | 123,000 | **154,000** | 31,000 | 164,000 | **195,000** | **១៥ ថ្ងៃ** ថ្ងៃការងារ (៣) |
| **1 x 10** | 62,000 | 62,000 | **124,000** | 62,000 | 246,000 | **308,000** | 62,000 | 328,000 | **390,000** | |
| **1 x 20** | 228,000 | 123,000 | **351,000** | 228,000 | 492,000 | **720,000** | 228,000 | 656,000 | **884,000** | |
| **1 x 32** | 368,000 | 394,000 | **762,000** | 368,000 | 787,000 | **1,155,000** | 368,000 | 1,050,000 | **1,418,000** | |
| **1 x 63** | 736,000 | 775,000 | **1,511,000** | 736,000 | 1,550,000 | **2,286,000** | 736,000 | 2,066,000 | **2,802,000** | |
| **3 x 32** | 1,104,000 | 1,181,000 | **2,285,000** | 1,104,000 | 2,362,000 | **3,466,000** | 1,104,000 | 3,149,000 | **4,253,000** | **៤៥ ថ្ងៃ** ថ្ងៃធម្មតា (៤) |
| **3 x 40** | 1,368,000 | 1,476,000 | **2,844,000** | 1,368,000 | 2,952,000 | **4,320,000** | 1,368,000 | 3,936,000 | **5,304,000** | |
| **3 x 63** | 2,208,000 | 2,325,000 | **4,533,000** | 2,208,000 | 4,650,000 | **6,858,000** | 2,208,000 | 6,199,000 | **8,407,000** | |
| **3 x 100** | 3,300,000 | 3,690,000 | **6,990,000** | 3,300,000 | 7,380,000 | **10,680,000** | 3,300,000 | 9,840,000 | **13,140,000** | |

**កំណត់ចំណាំ** (១). អតិថិជនមិនត្រូវបង់ប្រាក់លើសពីតារាងខាងលើឡើយ ។

(២). រយៈពេលផ្តល់សេវាគឺគិតពីថ្ងៃទទួលពាក្យ រហូតដល់ថ្ងៃភ្ជាប់ចរន្តដោយមិនគិតពីការយឺតយ៉ាវរបស់អ្នកស្នើសុំដូចជា៖

- បំពេញឯកសារពុំគ្រប់តាមការតម្រូវ ដូចក្នុងទម្រង់ពាក្យសុំបន្តចរន្តអគ្គិសនី និង/ឬ យឺតយ៉ាវក្នុងការមកចុះហត្ថលេខា លើកិច្ចសន្យាជាវចរន្ត និង/ឬ ពន្យាពេលក្នុងការបង់ប្រាក់ ។
- ពុំទាន់មានសម្ភារ ដែលជាបន្ទុករបស់អតិថិជន ។

(៣). ថ្ងៃការងារ គិតពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកដែលប្រកាសដោយអនុក្រឹត្យនៃរាជរដ្ឋាភិបាល។

(៤). ថ្ងៃធម្មតា គិតទាំងថ្ងៃឈប់ និងថ្ងៃការងារ ។

**បញ្ជាក់** - ក្នុងករណីមានការយឺតយ៉ាវ ជាងរយៈពេលកំណត់ខាងលើ អគ្គិសនីកម្ពុជា នឹងផ្តល់ជូនព័ត៌មានដល់អតិថិជនជាលាយលក្ខណ៍អក្សរ ។

- ការបន្តចរន្តថ្មី ឬតម្លើងកម្លាំង អាចផ្តល់ជូនបានលុះត្រា បំណុលថ្លៃភ្លើងនៅទីតាំងនោះ ត្រូវបានទូទាត់ជាមុនសិន ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**